ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MOSALVY

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ២៨៨ សករបយ.

ភ្នំពេញ, ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០០១

# ប្រកាស
## ស្តីពី
## សេចក្តីប្រកាសជូនដំណឹងបើក និងបិទសហគ្រាស គ្រឹះស្ថាន

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកប/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## សំរេច

**ប្រការ១.-** នាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថានដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារ ត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថានទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នៅមុនពេលបើកសហគ្រាស គ្រឹះស្ថាន ជាស្ថាពរ ។-

**ប្រការ២.-** សំណុំលិខិត នៃសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថានមានដូចតទៅ :-

១-សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថានយកតាមគំរូក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ ដោយមានបិទតែមប្រ៍ ១.៥០០រៀល ( មួយពាន់ប្រាំរយរៀល ) ចំនួនពីរច្បាប់ ។

២-សេចក្តីប្រកាសជូនដំណឹងស្តីអំពីបុគ្គលិកយកតាមគំរូក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ ចំនួនបីច្បាប់។

ចំពោះសហគ្រាស គ្រឹះស្ថានទាំងអស់នៅក្នុងរាជធានីភ្នំពេញត្រូវបញ្ជូនសំណុំលិខិតនៃសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថានខាងលើ ទៅនាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចំណែកសហគ្រាស គ្រឹះស្ថាននៅតាមខេត្ត-ក្រុងផ្សេងទៀត ត្រូវបញ្ជូនទៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង នៃមូលដ្ឋានខ្លួន។

<u>ប្រការ៣</u>.- សហគ្រាស គ្រឹះស្ថានទាំងអស់ដែលមានចង្អុលបង្ហាញក្នុងប្រការ១ ខាងលើ ត្រូវជូនដំណឹងមកនាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចំពោះសហគ្រាស គ្រឹះស្ថាននៅរាជធានីភ្នំពេញ ឬមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុងនៃមូលដ្ឋានខ្លួន នូវគ្រប់សកម្មភាពផ្លាស់ប្តូរទីតាំង ការកែប្រែរចនាសម្ព័ន្ធផលិតកម្ម ការផ្លាស់ប្តូរម្ចាស់ និងការបិទ ឬបញ្ឈប់សកម្មភាពសហគ្រាសយ៉ាងយូរបំផុត៣០ ថ្ងៃ ( សាមសិបថ្ងៃ ) បន្ទាប់ពីថ្ងៃមានការផ្លាស់ប្តូរ ឬបន្ទាប់ពីថ្ងៃដែលបញ្ឈប់សកម្មភាពសហគ្រាស គ្រឹះស្ថាន។

<u>ប្រការ៤</u>.- អ្នកប្រព្រឹត្តិល្មើសនឹងបទបញ្ញត្តិ នៃប្រកាសនេះត្រូវទទួលការពិន័យ ឬផ្តន្ទាទោសដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ។

<u>ប្រការ៥</u>.- ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ១៤៧ សកអ.ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៧ ត្រូវចាត់ទុកជានិរាករណ៍។

<u>ប្រការ៦</u>.- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ រដ្ឋមន្ត្រី

<u>**ចម្លងជូន**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ

" ដើម្បីជូនជ្រាប "

- អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

- សមាគមនិយោជក
- សហព័ន្ធសហជីព

" ដើម្បីជ្រាប "

- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ "
- រាជកិច្ច
- កាលប្បវត្តិ និងឯកសារ

អ៊ិត សំហេង

ឧបសម្ព័ន្ធទី១
នៃប្រកាសលេខ :..................
ចុះថ្ងៃទី .......ខែ .........ឆ្នាំ ............

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស

១. ឈ្មោះនៃសហគ្រាស..................................................................................................

២. កាលបរិច្ឆេទនៃការបើក , ថ្ងៃទី..................ខែ..........................ឆ្នាំ ......

៣. អាសយដ្ឋាននៃទីស្នាក់ការសហគ្រាស លេខ ........................ ផ្លូវ............................ , សង្កាត់.........................
ខណ្ឌ...............................ក្រុង ............................ លេខទូរស័ព្ទ................................ លេខទូរសារ...................
- ឈ្មោះម្ចាស់សហគ្រាស ................................................................................សញ្ជាតិ......................
- ឈ្មោះនាយកសហគ្រាស ..............................................................................សញ្ជាតិ......................

៤. លក្ខន្តិកៈគតិយុត្តិរបស់សហគ្រាស (១) ..............................................................................

៥. ប្រភេទសហគ្រាស (២) .........................................................................................

៦. ទីតាំងនៃសហគ្រាស លេខ ....................... ផ្លូវ.......................... សង្កាត់.......................ខណ្ឌ.......................
ក្រុង ........................... លេខទូរស័ព្ទ.............................. លេខទូរសារ.....................................................

៧. ចំនួននិយោជិត កម្មករ សរុប ........................នាក់ ស្រី .............. នាក់ ប្រុស ..................... នាក់
ក្នុងនោះ :
- មានកម្មករ និយោជិត អាយុពី ១៥ ឆ្នាំទៅក្រោម ១៨ ឆ្នាំ ចំនួន ...................... នាក់
ស្រី .................. នាក់ ប្រុស .................. នាក់
- មានជនបរទេស ចំនួន ............... នាក់ ស្រី ...................... នាក់ ប្រុស ...................... នាក់

៨. រយៈពេលនិងប្រភេទការងារពេលយប់សម្រាប់ស្ត្រី ឬ ក្មេងប្រុសនិងក្មេងជាងបង្ហាត់ ........................
.......................................................................................................................................
.......................................................................................................................................
.......................................................................................................................................

៩. មានកម្មករ និយោជិតអាយុក្រោម ១៨ ឆ្នាំ ស្នាក់នៅក្នុងសហគ្រាសចំនួន........នាក់ (ស្រី........នាក់)

១០. ប្រភេទនៃគ្រឿងចក្រ និងវិធីប្រើសំភារៈ ទប់ស្កាត់ដើម្បីការពារគ្រោះថ្នាក់ ..............................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

១១. ថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ ..............................................................................................

ភ្នំពេញ,ថ្ងៃទី..............ខែ....................ឆ្នាំ ....

ហត្ថលេខា ម្ចាស់ ឬ នាយកសហគ្រាស

<u>កំណត់សំគាល់ :</u>

(១): សូមបញ្ជាក់ត្រង់ចំណុចនេះថា :

-ជាក្រុមហ៊ុនអនាមិក

-ឬ ជាក្រុមហ៊ុនទទួលខុសត្រូវមានកំណត់

-ឬ ជាក្រុមហ៊ុនមូលធន

-ឬ ជាសហគ្រាសឯកជន

(២): សូមបញ្ជាក់ត្រង់ចំណុចនេះថា :

-ជាសហគ្រាសឧស្សាហកម្ម

-ឬ ជាសហគ្រាសសំណង់

-ឬ ជាសហគ្រាសពាណិជ្ជកម្ម

-ឬ ជាសហគ្រាសសេវាកម្ម

-ឬ ជាសហគ្រាសសិប្បកម្ម

-ឬ ជាសហគ្រាសកសិកម្ម

ឧបសម្ព័ន្ធទី២
នៃប្រកាសលេខ :.................
ចុះថ្ងៃទី ........ខែ .........ឆ្នាំ ............

# សេចក្តីប្រកាសជូនដំណឹងស្តីពីបុគ្គលិក

| | | |
|---|---|---|
| ឈ្មោះ:............................................<br>អាសយដ្ឋាន:ផ្ទះលេខ:.............ផ្លូវ:.............សង្កាត់:.............<br>ខណ្ឌ:......................ក្រុង:......................ទូរស័ព្ទ:.............<br>ឈ្មោះម្ចាស់គ្រឹះស្ថាន:............................សញ្ជាតិ:.............<br>ឈ្មោះនាយកគ្រឹះស្ថាន:............................សញ្ជាតិ:............. | ថ្ងៃចាប់ផ្តើមសកម្មភាពសេដ្ឋកិច្ច:....................................................<br>ផលិតផលសំខាន់:....................................................<br>លក្ខន្តិកៈគតិយុត្តនៃសហគ្រាស:.................................................... | ចំនួនបុគ្គលិកសព្វថ្ងៃ:.........................នាក់<br>ចំនួនបុគ្គលិកបម្រុង: (១) ..............នាក់<br>គិតត្រឹមថ្ងៃទី..........ខែ............ឆ្នាំ |

| ល.រ | នាមត្រកូល និងនាមខ្លួន | ភេទ | សញ្ជាតិ | ថ្ងៃខែឆ្នាំកំណើត | លេខសៀវភៅការងារ | សៀវភៅប្រចាំខែ | របៀបបើកប្រាក់ | ថ្ងៃខែឆ្នាំចូលធ្វើការ | មុខងារ | កំរិតវប្បធម៌ ឬ កំរិតវិជ្ជាជីវៈ | ចំនួនម៉ោងធ្វើការក្នុងមួយសប្តាហ៍ | កំណត់សំគាល់របស់ការិយាល័យ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | ១៣ | ១៤ |
| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | | |
| | ក_អ្នកដឹកនាំ | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | ខ_និយោជិតការិយាល័យ | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | គ_កម្មករជំនាញខ្ពស់ | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | ឃ_កម្មករជំនាញ , | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | ង_កម្មករពាក់កណ្តាលជំនាញ | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | ច_ហត្ថករឯកទេស | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | ឆ_ហត្ថករ | | | | | | | | | | | | |
| | | | | | | | | | | | | | |

**កំណត់សំគាល់** : - [illegible]
[illegible]
- (១) [illegible]

ធ្វើនៅថ្ងៃទី..........ខែ..........ឆ្នាំ..........
ហត្ថលេខាម្ចាស់ ឬនាយកសហគ្រាស